វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកល វិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ទីស្តីការគណៈរដ្ឋមន្ត្រី
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
សង្ខេបសម្រាប់
គោលនយោបាយ
ឆ្នាំ ២០១២ លេខ ០៥

# ការវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើគ្រួសារក្រីក្រនៅតំបន់ជនបទ៖ ផលវិបាក និងអាទិភាពគោលនយោបាយ*

*ដោយ ទ្រី សុជារឹទ្ធ*[១]

## សេចក្តីផ្តើម

មានឯកសារជាច្រើនបញ្ជាក់ថា វិបត្តិហិរញ្ញវត្ថុសាកល (GFC) បានបង្កការរួមចុះខ្លាំងក្នុងវិស័យជំរុញកំណើនសំខាន់ៗរបស់កម្ពុជា ពោលគឺ វិស័យកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍។ អត្ថបទសង្ខេបគោលនយោបាយនេះ វាយតម្លៃថា តើការរួមចុះផ្នែកម៉ាក្រូសេដ្ឋកិច្ចទាំងនេះ បានប៉ះពាល់ជាក់ស្តែងដល់សេដ្ឋកិច្ចគ្រួសារនៅជនបទឬទេ ដោយប្រើប្រាស់លទ្ធផលវិភាគសេដ្ឋកិច្ច-សង្គមកិច្ចលើ ៥ភូមិ ទទួលបានពីទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់នៃប្រព័ន្ធត្រួតពិនិត្យផ្អែកលើសហគមន៍ (CBMS) ឆ្នាំ ២០០៦ ឆ្នាំ២០០៨ និងនៅក្រោយ GFC ក្នុងឆ្នាំ២០១១។

អត្ថបទនេះ មានវត្ថុបំណងបីយ៉ាងគឺ៖ ១) វិភាគពីផលប៉ះពាល់នៃ GFC ទៅលើទិដ្ឋភាពផ្សេងៗនៃភាពក្រីក្រ នៅកម្រិតគ្រួសារ ២) កំណត់ពីយន្តការដោះស្រាយផ្សេងៗដែលគ្រួសារបានប្រើប្រាស់ និងឥទ្ធិពលនៃយន្តការទាំងនោះ លើសុខុមាលភាពរយៈពេលវែងរបស់ពួកគេ និង ៣) វាយតម្លៃពីប្រសិទ្ធភាពនៃគោលនយោបាយរដ្ឋាភិបាល ក្នុងការកាត់បន្ថយឥទ្ធិពលវិបត្តិ និងស្នើឡើងនូវវិធីសាស្រ្តថ្មីៗមួយចំនួន។

## ផលប៉ះពាល់នៃវិបត្តិទៅលើគ្រួសារនៅជនបទ

ការរួមចុះនៃ ទីផ្សារការងារក្នុងវិស័យសំខាន់ៗនៅកម្ពុជា ដែលបង្កឡើងដោយ វិបត្តិហិរញ្ញវត្ថុសាកល (GFC) បានជះឥទ្ធិពលអវិជ្ជមានទៅលើពលករចំណាកស្រុក និងអ្នកទទួលផលពីប្រាក់ផ្ញើមកផ្ទះ។ ការបាត់បង់ការងារមួយភាគធំក្នុងអំឡុងពេលវិបត្តិហិរញ្ញវត្ថុសាកល អាចជាផលប៉ះពាល់នៃវិបត្តិនេះ។ តួយ៉ាង ១១% នៃការងារបាត់បង់ក្នុងអំឡុងពេលនោះ គឺមកពីការបិទទ្វារក្រុមហ៊ុន ដោយសារតម្រូវការពីអតិថិជនបានថយចុះ។ ការធ្លាក់ចុះឧស្សាហកម្មសំណង់ និងការរលំរលាយតម្រូវការផ្នែកអចលនទ្រព្យ បានប៉ះពាល់យ៉ាងខ្លាំងបំផុត ដោយបង្ករហូតដល់ ២៦% នៃការងារដែលបានបាត់បង់ទាំងអស់។

គ្រួសារក្រីក្របានរងគ្រោះធ្ងន់ធ្ងរលើសលុបពី GFC ដោយមាន ៦% នៃសមាជិកគ្រួសារក្រីក្រ បានបាត់បង់ការងារ ក្នុងអំឡុងពេល GFC ធៀបនឹងត្រឹម ៤% សម្រាប់គ្រួសារមិនក្រីក្រ។

ការរួមចុះនៃទីផ្សារការងារ កាន់តែយ៉ាប់យ៉ឺនថែមទៀតតាមរយៈការកាត់បន្ថយចំនួនម៉ោងធ្វើការ ដែលធ្វើឲ្យថយចុះលទ្ធភាពរកចំណូលរបស់គ្រួសារ។ ជាលទ្ធផល មានគ្រួសារ ៣៧% បានបាត់បង់ចំណូលប្រចាំឆ្នាំប្រហែល ៥០០ដុល្លារ ឬលើសពីនេះ ដែលបានពីប្រាក់ផ្ញើមកផ្ទះ គឺស្មើនឹងប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំបានពីការដាំដុះស្រូវលើផ្ទៃដីពី ១ ទៅ ៣ ហិកតា នៅក្នុងភូមិដែលបានចុះសិក្សានានា។ ការបាត់បង់នេះ បានប៉ះពាល់ខ្លាំងគួរសមដល់ប្រាក់ចំណូលរបស់គ្រួសារនៅជនបទ ជាពិសេស គ្រួសារក្រីក្រ។

## តើគ្រួសារនៅជនបទទប់ទល់យ៉ាងដូចម្តេចនឹងវិបត្តិហិរញ្ញវត្ថុសាកល?

ក្នុងអំឡុងពេល វិបត្តិហិរញ្ញវត្ថុសាកល គ្រួសារនានាបានផ្តល់អាទិភាពលើសន្តិសុខស្បៀង តាមរយៈ ការប្រើប្រាស់របស់ដែលខ្លួនអាចផលិតបានជាជាងទិញពីគេ ដូចជា ការជំនួសសាច់ និងបន្លែដោយអាហារមូលដ្ឋាន (ដូចជា អង្ករ), ការទិញអាហារថោកៗ និងការកាត់បន្ថយចំណាយជាទូទៅរបស់គ្រួសារ លើស្បៀងអាហារ។ គ្រួសារមានបុរសជាមេគ្រួសារ (MHH) មានសមត្ថភាពអាចកាត់បន្ថយចំណាយ ដោយគាត់បង្កើនការផលិត រីឯគ្រួសារមានស្ត្រីជាមេគ្រួសារ (FHH) ពឹងផ្អែកច្រើនទៅលើការទិញអាហារមានគុណភាពទាបជាងមុន។ តួយ៉ាង ៦៥% នៃគ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ បានទិញអាហារមានគុណភាពទាបជាងមុន ក្នុងអំឡុងពេល វិបត្តិហិរញ្ញវត្ថុសាកល ធៀបនឹងត្រឹម ៥៦% សម្រាប់ក្រុមគ្រួសារក្រីក្រមានបុរសជាមេគ្រួសារ។ លំនាំនេះ បង្ហាញពីការថយចុះជាទូទៅនៃគុណភាពអាហារូបត្ថម្ភ នៅក្នុងរបបអាហាររបស់ប្រជាជននៅជនបទ ដែលអាចជះឥទ្ធិពល

* ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។

[១] លោក ទ្រី សុជារឹទ្ធ ជាអ្នកដឹកនាំ ប្រព័ន្ធត្រួតពិនិត្យផ្អែកលើសហគមន៍ (CBMS) នៃ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

អវិជ្ជមានទៅលើ ផលិតភាពរបស់គ្រួសារ ជាពិសេសសម្រាប់គ្រួសារមានស្ត្រីជាមេគ្រួសារ។

វិបត្តិហិរញ្ញវត្ថុសាកល បានធ្វើឲ្យមានកំណើនការប្រើពលកម្មកុមារ ដោយសារគ្រួសារទាំងនោះត្រូវតស៊ូទប់ទល់នឹងការថយចុះប្រាក់ចំណូល ជាពិសេស គ្រួសារក្រីក្រ។ ដើម្បីសន្សំប្រាក់ គ្រួសារជាច្រើនបានជំរុញឲ្យកូនៗបោះបង់ការសិក្សា ដើម្បីជួយរកចំណូល។ ប្រហែល ៥% នៃគ្រួសារមិនក្រីក្រ និង ១២% នៃគ្រួសារក្រីក្រ បានជំរុញឲ្យកូនៗបោះបង់ការសិក្សា ឬក៏មិនទៅសាលារៀននៅថ្ងៃខ្លះដើម្បីនៅជួយធ្វើការ។ ប្រសិនបើនិន្នាការនេះបន្តទៅមុខទៀត សក្តានុពលសកម្មភាពសេដ្ឋកិច្ចទៅថ្ងៃអនាគតរបស់គ្រួសារនៅជនបទ នឹងធ្លាក់ចុះ ហើយគ្រួសារក្រីក្រនឹងត្រូវរងគ្រោះខ្លាំងជាងគេ។

គ្រួសារជាច្រើន (៦៧%) ក្នុងអង្កេតនៃប្រព័ន្ធត្រួតពិនិត្យផ្អែកលើសហគមន៍ (CBMS) បានទទួលយកកម្ចី ដើម្បីបំពេញកង្វះខាតផ្នែកចំណាយ (រូបភាព ១)។ ជារឿយៗ គ្រួសារទាំងនេះ ពិសេស គ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ ត្រូវទទួលយកកម្ចីមានការប្រាក់ខ្ពស់ ពីអ្នកផ្តល់កម្ចីមិនផ្លូវការ។ តួយ៉ាង សម្រាប់គ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ ប្រាក់កម្ចីទទួលបានពីអ្នកផ្តល់កម្ចីមិនផ្លូវការ មាន ៣៩% ធៀបនឹងអត្រាជាមធ្យម ៣១% សម្រាប់គ្រួសារទាំងអស់។ ក្នុងដំណើរការអភិវឌ្ឍជាវិជ្ជមាន អ្នកផ្តល់ឥណទានដែលជា ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) និងអង្គការមិនមែនរដ្ឋាភិបាល (NGO) កំពុងដើរតួនាទីកាន់តែសកម្ម នៅក្នុងទីផ្សារឥណទានជនបទ និងផ្តល់ជាជម្រើសមួយទៀត ក្រៅពីអ្នកផ្តល់កម្ចីមិនផ្លូវការ។ ទោះយ៉ាងណា គ្រួសារងាយរងគ្រោះនានា ជាពិសេសគ្រួសារមានស្ត្រីជាមេគ្រួសារ ហាក់នៅតែលំបាកនឹងទទួលបានសេវាកម្មទាំងនោះ ដោយមាន ៣៣% ប៉ុណ្ណោះនៃកម្ចីផ្តល់ទៅឲ្យគ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ ដែលមានប្រភពពីអ្នកផ្តល់កម្ចីជា NGO/MFI ធៀបនឹងអត្រាជាមធ្យម ៤៥% សម្រាប់គ្រួសារទាំងអស់។

រូបភាព ១៖ ប្រភពកម្ចីនៅក្នុងគ្រួសារ CBMS




## ចម្លើយតបរបស់រដ្ឋាភិបាល៖ នាបច្ចុប្បន្ន និងទៅអនាគត

រដ្ឋាភិបាល បានចាប់អនុវត្តគំនិតផ្តួចផ្តើមធ្វើគោលនយោបាយជាច្រើន ដើម្បីសម្រាលឥទ្ធិពលអវិជ្ជមាននៃ GFC មានជាអាទិ៍ការផ្គត់ផ្គង់អង្ករមានឧបត្ថម្ភធន និងការបង្កើតមូលនិធិសុខភាពសម្រាប់គ្រួសារក្រីក្រ។ ប៉ុន្តែការឆ្លើយតបនានា ច្រើនតែមានលក្ខណៈចំពោះកិច្ច។ គោលនយោបាយទៅថ្ងៃខាងមុខ គួរពាក់ព័ន្ធឲ្យបានគ្រប់ផ្នែក និងធ្វើការជាប្រព័ន្ធ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃជីវភាពនៅជនបទ តាមការកសាងភាពធន់ទ្រាំរបស់គ្រួសារទៅនឹងវិបត្តិនានា ពិសេសក្នុងចំណោមគ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ។

ក្នុងគោលនយោបាយ គួរផ្តល់អាទិភាពដល់ការកសាងប្រព័ន្ធការពារសង្គមគ្រប់ជ្រុងជ្រោយមួយ ដែលជួយកសាងសមត្ថភាពសហគមន៍ក្នុងការឆ្លើយតប ប្រកបដោយប្រសិទ្ធភាពទៅនឹងវិបត្តិនានា។ បច្ចុប្បន្ន រដ្ឋាភិបាលកំពុងបង្កើតប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលគួរទទួលបានហិរញ្ញប្បទានប្រកបដោយចីរភាព។ គម្រោងនេះ គួរគ្របដណ្តប់លើផ្នែកផ្សេងៗជាច្រើន ដោយរួមបញ្ចូលទាំងអន្តរាគមន៍ដែលផ្តោតជាពិសេសលើជនក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួសារ កម្មវិធីការងារសាធារណៈ និងការផ្ទេរប្រាក់ និងគួរមានរចនាសម្ព័ន្ធរដ្ឋបាលឯកភាព និងមានប្រសិទ្ធភាពល្អមួយ។

គួរកត់សម្គាល់ថា វិបត្តិហិរញ្ញវត្ថុសាកល វាប៉ះទង្គិចដល់ទីជនបទតាមច្រកដ៏សំខាន់មួយ គឺការកាត់បន្ថយចំណូលបានពីការងារមិនមែនកសិកម្ម ជាពិសេស ប្រាក់ផ្ញើមកផ្ទះ។ ស្រដៀងគ្នានេះដែរ ចំណូលពីការងារជំនួញតូចតាច ជាយុទ្ធសាស្ត្រទប់ទល់ដ៏សំខាន់មួយសម្រាប់គ្រួសារដែលរងផលប៉ះពាល់ពី វិបត្តិហិរញ្ញវត្ថុសាកល ជាពិសេស គ្រួសារក្រីក្រមានស្ត្រីជាមេគ្រួសារ។ ដូច្នេះ គោលនយោបាយដែលបង្កើតឡើង គួរផ្តោតលើយុទ្ធសាស្ត្រចិញ្ចឹមជីវិតនៅតំបន់ជនបទ ក្រៅពីវិស័យកសិកម្ម ហើយក្នុងនេះការលើកកម្ពស់លទ្ធភាពចូលទៅកាន់ទីផ្សារ តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការបង្កើនព័ត៌មាន តាមរយៈគម្រោងបណ្តុះបណ្តាលផ្សេងៗ គឺជាអាទិភាពគោលនយោបាយសំខាន់ៗបំផុត។

គោលនយោបាយដែលសំដៅបង្កើនផលិតភាព របស់កសិករតូចតាចក៏សំខាន់ណាស់ដែរ ដើម្បីពង្រឹងភាពធន់ទ្រាំរបស់គ្រួសារទៅនឹងវិបត្តិនានា។ គោលនយោបាយទាំងនោះ មានដូចជាការធានាលទ្ធភាពប្រើប្រាស់ដីធ្លីនិងធនធានទឹក ការកែលំអប្រព័ន្ធស្រោចស្រពនិងហេដ្ឋារចនាសម្ព័ន្ធ ការជំរុញរបៀបធ្វើកសិកម្មបែបទំនើប និងការពង្រីកសេវាកម្មនិងប្រាក់កម្ចីសម្រាប់វិស័យកសិកម្ម ទៅឲ្យកសិករតូចតាច។